សូមអានក្រដាសព័ត៌មានដែលមានផ្លាស់ប្តូរកន្លែងចែកអាហារថ្មី

## កន្លែងចែកអាហារមានការផ្លាស់ប្តូរជាថ្មី ក្រុមប៊ុគ **Chromebook** នៅមានចែកឱ្យសិស្សនៅថ្ងៃច័ន្ទទី៣០ មិនា នៅពីរកន្លែង(សាលារៀន)

ចាប់ផ្តើមពីថ្ងៃច័ន្ទ ទី៣០ខែមិនា ក្រសួងអប់រំឡុងប៊ីចនឹងផ្តល់សេវាចែកអាហារដល់កុមារនៅតាមសាលារៀនមួយចំនួនដែលជាទីតាំងចែកអាហារថ្មី។ ថែមពីនោះទៀត ការចែកក្រុមប៊ុគ Chromebook សម្រាប់សិស្សនៅក្នុងក្រសួងអប់រំ LBUSD ដែលនៅត្រូវការឧបករណ៍នេះសម្រាប់ប្រើប្រាសអ៊ិនធើនែត នឹងមានបន្តចែកឱ្យនៅតាមសាលារៀនពីរ នៅក្នុងពេលម៉ោងចែកចាយដូចចែងនៅខាងក្រោម។ ក្រសួងអប់រំនៅតែបន្តផ្តល់ឱកាសសិក្សានៅផ្ទះ **Home Learning Opportunities** នៅគេហទំព័រ lbschools.net/HLO ដែលអាចចូលទៅបានដោយប្រើក្រុមប៊ុគឬឧបករណ៍ផ្សេងទៀត។

## អាហារ

LBUSD នឹងផ្តល់អាហារសម្រាប់យកទៅញុំានៅផ្ទះដល់កុមារអាយុមួយឆ្នាំដល់ ១៨ឆ្នាំនៅ ក្នុងរយៈពេលដែលសាលាបិទទ្វារនៅសាលា: Addams, Avalon, Birney, Bixby, Burbank, Chavez, Dooley, Emerson, Gant, Garfield, Gompers, Grant, Harte, Henry, Herrera, King, Lafayette, Lincoln, Lindbergh, Longfellow, MacArthur, Marshall, McKinley, Muir, Riley, Rogers, Roosevelt, Signal Hill, Smith, Stevenson, Twain, Washington, Whittier and Willard. រកមើលផែនទីសាលារៀន ដោយចូលទៅគេហទំព័រក្រសួងអប់រំនៅ lbschools.net រួចចុច ABOUT > Map ។

អាហារមានចែកឱ្យពីម៉ោង 11:30 ព្រឹក ទៅដល់ម៉ោង 12:30 ថ្ងៃ ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។

អាហារនេះផ្តល់ឱ្យដោយមិនគិតតម្លៃដល់សិស្សទាំងអស់ មិនថាឡើយសិស្សទៅរៀននៅសាលារៀនណាមួយក៏ដោយ ហើយមិនចាំបាច់បង្ហាញក្រដាសស្នាមអ្វីទេ។ សិស្សត្រូវតែមានវត្តមានមកយកអាហារដោយខ្លួនឯង។

### ក្រុមប៊ុគ **Chromebooks**

មាតាបិតា / អាណាព្យាបាលដែលនៅត្រូវការក្រុមប៊ុគសម្រាប់កូនគាត់ត្រូវតែយកអត្តសញ្ញាណប័ណ្ណដែលមានរូបរបស់គាត់ ព្រមទាំងអត្តសញ្ញាណប័ណ្ណសាលារបស់កូនគាត់ទៅសុំក្រុមប៊ុគមួយនៅសាលាណាមួយក្នុងចំណោមសាលាទាំង៥ខាងក្រោមនេះ ។ ការចែកក្រុមប៊ុគនឹងមានចែកពីម៉ោ៨ព្រឹកទៅ១១ព្រឹក នៅថ្ងៃច័ន្ទទី៣០ខែមិនា នៅតាមសាលារៀនទាំងពីរខាងក្រោមនេះ

- វិទ្យាល័យ Jordan High School, 6500 Atlantic Ave., Long Beach
- វិទ្យាល័យ Poly High School, 1600 Atlantic Ave., Long Beach

ការណែនាំរបៀបប្រើប្រាសក្រុមប៊ុគព្រមទាំង ព័ត៌មានសម្រាប់ដាក់អ៊ិនធើនែតចុះតម្លៃនឹងមានផ្តល់ឱ្យនៅពេលទៅយកក្រុមប៊ុគ។